# សេចក្តីថ្លែងការណ៍ក្រុងម៉េលប៊ិន

នៅទីជំនួបជាប្រពៃណីរបស់ក្រុមមនុស្ស Wurungdjeri, Boonerwrung, Taungurong, Djajawurrung និង Wathaurung ជាអ្នកដែលបានថែរក្សាទឹកដីមុនដំបូងគេបង្អស់ និង រឹងមាំ ដែលបានបង្កើតឡើងនូវប្រជាជាតិ Kulin យើងជួបជុំគ្នានៅក្រុងម៉េលប៊ិន ដើម្បីវាយតម្លៃវឌ្ឍនភាពនៃការឆ្លើយតបទៅនឹងជំងឺអេដស៍ជាសកល និង ទិសដៅអនាគត នៅក្នុងសន្និសីទអន្តរជាតិលើកទី២០ ស្តីពីជំងឺអេដស៍ ឆ្នាំ២០១៤ ។

យើងជាហត្ថលេខី និង ជាអ្នកផ្តល់ការគាំទ្រលើសេចក្តីប្រកាសនេះ សូមបញ្ជាក់អះអាងថា ការមិនរើសអើង គឺជាមូលដ្ឋានគ្រឹះនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ដោយផ្អែកលើភ័ស្តុតាង ផ្អែកលើសិទ្ធិ និង ការផ្លាស់ប្តូរយេនឌ័រ និង គម្រោងកម្មវិធីសុខភាពសាធារណៈដែលប្រកបដោយប្រសិទ្ធភាព ។

ដើម្បីយកឈ្នះមេរោគអេដស៍ និង សម្រេចបានការទទួលបានសេវាបង្ការមេរោគអេដស៍ ព្យាបាល ថែទាំ និង គាំទ្រ ជាសកលនោះ គឺគ្មាននរណាម្នាក់ត្រូវបានធ្វើឱ្យក្លាយជាឧក្រិដ្ឋជន ឬរើសអើង ដោយសារតែ ភេទ អាយុ ជាតិសាសន៍ អំបូរជនជាតិ ពិការភាព សាសនា ឬជំនឿ ប្រទេសកំណើត ស្ថានភាពប្រទេសជាតិ ទំនោរផ្លូវភេទ អត្តសញ្ញាណភេទ ឋានៈរបស់ពួកគេជាអ្នកបម្រើសេវាផ្លូវភេទ ពិរុទ្ធជន ឬ ជនជាប់ឃុំឃាំង ដោយសារតែពួកគេប្រើប្រាស់ ឬបានប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ឬក៏ដោយសារពួកគេកំពុងតែរស់នៅជាមួយនឹងមេរោគអេដស៍ឡើយ ។

យើងសូមបញ្ជាក់អះអាងថា មនុស្សគ្រប់រូប ស្ត្រី បុរស អ្នកកែភេទ អន្តរភេទ ជាមនុស្សពេញវ័យ និង កុមារ ត្រូវទទួលបានសិទ្ធិស្មើភាព និង ទទួលបានដូចគ្នានូវសិទ្ធិទទួលសេវាបង្ការមេរោគអេដស៍ ថែទាំ និង ព្យាបាល ព័ត៌មាន និងសេវាកម្ម ។ ការលើកកម្ពស់សមភាពយេនឌ័រគឺមានសារៈសំខាន់ក្នុងការឆ្លើយតបទាំងឡាយទៅនឹងមេរោគអេដស៍ ដែលពិតជាស្របទៅនឹងតម្រូវការរបស់អ្នកដែលរងផលប៉ះពាល់ខ្លាំងបំផុត ។ លើសពីនេះ អ្នកដែលលក់ និង បានលក់

សេវាផ្លូវភេទ អ្នកប្រើប្រាស់ ឬអ្នកដែលបានប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ត្រូវបានទទួលសិទ្ធិដូចអ្នកដទៃទៀតដែរ រួមទាំងការមិនរើសអើង និង ការរក្សាការសម្ងាត់ក្នុងការទទួលសេវាថែទាំ និង ព្យាបាលមេរោគអេដស៍ ។

យើងសូមសម្តែងពីក្តីកង្វល់ជារួម និង ធំធេងរបស់យើង ចំពោះការបន្តនូវការពង្រឹងការអនុវត្តច្បាប់ដែលមានលក្ខណៈរើសអើង បន្ទាបបន្ថោក ដាក់ឱ្យក្លាយទៅជាព្រហ្មទណ្ឌ និង បង្កឱ្យមានគ្រោះថ្នាក់ ដែលបណ្តាលឱ្យគោលនយោបាយ និង ការអនុវត្តន៍គោលនយោបាយបង្កើននូវភាពងាយរងគ្រោះចំពោះមេរោគអេដស៍ ។ ច្បាប់ គោលនយោបាយ និង ការអនុវត្តទាំងនេះ បញ្ឆេះឱ្យមានអំពើហឹង្សាធ្ងន់ធ្ងរដល់ក្រុមប្រជាជនដែលគេទុកគន្លៀតជញ្ជាំង ពង្រឹងនូវអារម្មណ៍មិនទទួលយក និង បំផ្លាញកម្មវិធីប្រយុទ្ធនឹងមេរោគអេដស៍ ដែលទាំងនេះជាជំហានដើរថយក្រោយគួរឱ្យកត់សម្គាល់ចំពោះយុត្តិធម៌សង្គម សមធម៌ សិទ្ធិមនុស្ស ការទទួលបានសេវាថែទាំសុខភាព ទាំងអ្នកដែលកំពុងរស់នៅជាមួយមេរោគអេដស៍ និង អ្នកដែលងាយប្រឈមនឹងការឆ្លងមេរោគអេដស៍បំផុត ។

ប្រទេសជាង៨០ មានច្បាប់ដែលដាក់ទោសទណ្ឌខាងព្រហ្មទណ្ឌចំពោះអ្នកដែលមានទំនោរផ្លូវភេទផ្សេង ដែលមិនអាចទទួលយកបាន ។ មនុស្សទាំងអស់ រួមមាន ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកប្រព្រឹត្តផ្លូវភេទពីរភេទ អ្នកកែភេទ និង អ្នកអន្តរភេទ សុទ្ធតែមានសិទ្ធិដូចអ្នកដទៃទៀតដែរ ។ មនុស្សគ្រប់រូបកើតមកមានសិទ្ធិសេរីភាព និង ស្មើភាព ហើយជាសមាជិកស្មើភាពគ្នានៃគ្រួសារមនុស្សជាតិ។

អ្នកផ្តល់សេវាសុខភាពដែលរើសអើងជាមួយអ្នករស់នៅជាមួយមេរោគអេដស៍ ឬ ក្រុមងាយប្រឈមនឹងការឆ្លងមេរោគអដស៍ ឬការគំរាមកំហែងសុខភាពដទៃទៀត រំលោភបំពានលើកាតព្វកិច្ចនៃក្រុមសីលធម៌វិជ្ជាជីវៈរបស់ពួកគេ ក្នុងផ្តល់ការព្យាបាល និង ថែទាំមនុស្សដោយគ្មានភាពលម្អៀង ។

ដូច្នេះយើងសូមអំពាវនាវ ឱ្យមានការប្រឆាំងជាបន្ទាន់ និង រួមគ្នាចំពោះទង្វើរើសអើង និង អារម្មណ៍មិនទទួលយកទាំងនេះ ហើយទទូចសុំគ្រប់ភាគីទាំងអស់ឱ្យប្រកាន់យកវិធីសាស្ត្រដែលកាន់តែមានសមធម៌ និងមានប្រសិទ្ធភាព តាមរយៈសកម្មភាពដូចតទៅនេះ ៖

- រដ្ឋាភិបាលត្រូវតែលុបចោលច្បាប់ដែលបំបាក់ និង គោលនយោបាយដែលមានគោលដៅបង្កឱ្យមានការរើសអើង ការអនុវត្តដែលមិនទទួលយក ដែលបង្កើនភាពងាយរងគ្រោះចំពោះមេរោគអេដស៍ ដោយតាក់តែងច្បាប់ដែលលើកកម្ពស់សមភាពឱ្យបានសកម្មផងដែរ ។
- អ្នកធ្វើការសម្រេចចិត្ត មិនត្រូវប្រើប្រាស់កិច្ចប្រជុំ ឬសន្និសីទសុខាភិបាលអន្តរជាតិផ្សេងៗជាវេទិកា ដើម្បីលើកកម្ពស់ច្បាប់ និង គោលនយោបាយដែលមានលក្ខណៈរើសអើង ដែលបំផ្លាញសុខភាព និង សុខមាលភាព ។
- ការផាត់ចេញពីមូលនិធិផ្តល់ដោយម្ចាស់ជំនួយ ចំពោះកម្មវិធីមេរោគអេដស៍ អង្គការស្ថាប័នទាំងឡាយណាដែលលើកកម្ពស់ភាពមិនអត់ឱន និង ការរើសអើងប្រឆាំងទៅនឹងបុគ្គល ឬក្រុមមនុស្ស ដែលរួមមានការប្រកាន់ទំនោរផ្លូវភេទផ្សេង ការស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នា និង ភាពស្អប់ខ្ពើមអ្នកកែភេទ ។
- អ្នកផ្តល់សេវាថែទាំសុខភាពទាំងឡាយ ត្រូវបង្ហាញការអនុវត្តគោលនយោបាយមិនរើសអើង ដែលជាការបំពេញលក្ខខណ្ឌដំបូងសម្រាប់ការផ្តល់មូលនិធិគម្រោងកម្មវិធី នាពេលអនាគត ។
- រារាំងការផ្តល់មូលនិធិ ដូចជាការសន្យាប្រឆាំងនឹង ពេស្យាកម្ម ការហាមប្រាណការទិញម្ជុល និង សឺរ៉ាំង ត្រូវបានដកចេញ ដែលរារាំងស្ទះ យ៉ាងសកម្ម ចំពោះការប្រយុទ្ធប្រឆាំងមេរោគអេដស៍ ជំងឺឆ្លងផ្លូវភេទ ជំងឺរលាកថ្លើមប្រភេទC ក្នុងចំណោមអ្នកបម្រើសេវាផ្លូវភេទ និង អ្នកចាក់គ្រឿងញៀន ។

- ការផ្ដល់ការគាំទ្រជាសាធារណៈពីហត្ថលេខីទាំងអស់នៃសេចក្ដីប្រកាសនេះ ចំពោះគោលការណ៍រាប់បញ្ចូល អព្រហ្មទណ្ឌនីយកម្ម ការមិនរើសអើង និង ការអត់ឱនអធ្យាស្រ័យ ។

សរុបមក យើងសូមធ្វើការអះអាងនូវការប្ដេជ្ញាចិត្តមិនរាថយ ចំពោះសមធម៌ ការទទួលបានសេវាថែទាំ និង ព្យាបាលសុខភាពជាសកល និង គាំទ្រសេចក្ដីថ្លៃថ្នូរដែលមានជាប់មកជាមួយ និង សិទ្ធិមនុស្សជាតិទាំងអស់ ។

មនុស្សទាំងអស់ទទួលបានសិទ្ធិ និង ការការពារដែលអាចរកបានពីក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិ ។

ការលុបបំបាត់ជំងឺអេដស៍អាចធ្វើទៅបាន លុះត្រាតែយើងជំនះឧបសគ្គទាំងឡាយនៃព្រហ្មទណ្ឌនីយកម្ម អារម្មណ៍មិនទទួលយក និង ការរើសអើង ដែលនៅតែជាកត្តាជំរុញជាគន្លឹះនៃការឆ្លងរាលដាលមេរោគអេដស៍ ។

(សេចក្ដីថ្លែងការណ៍ដែលបកប្រែក្រៅផ្លូវការនេះ ដកស្រង់ទាំងស្រុងចេញពីគេហទំព័រ http://www.aids2014.org/declaration.aspx)